ក្រសួង ស្ថាប័នពាក់ព័ន្ធ និងឯកឧត្តមដែលមានឈ្មោះក្នុងប្រការ ២ ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
**ហ៊ុន សែន**

***

រាជធានីភ្នំពេញ, ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០០

## សេចក្តីសំរេចលេខ ៣១ សសរ

### ស្តីពីការបង្កើតគណៈកម្មការចំរុះកម្ពុជា -ឥណ្ឌា

****

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់ ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

### សំរេច

ប្រការ ១ : បង្កើតគណៈកម្មការចំរុះមួយ សំរាប់កិច្ចសហប្រតិបត្តិការកម្ពុជា- ឥណ្ឌា ដែលមានសមាសភាពដូចតទៅ:

| | | |
|---|---|---|
| ១- | រដ្ឋមន្ត្រីឬរដ្ឋលេខាធិការ នៃក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | ប្រធាន |
| ២- | តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣- | តំណាងក្រសួងការពារជាតិ | សមាជិក |
| ៤- | តំណាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ៥- | តំណាងក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៦- | តំណាងក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ៧- | តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | សមាជិក |
| ៨- | តំណាងក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | សមាជិក |
| ៩- | តំណាងក្រសួងទេសចរណ៍ | សមាជិក |

១០- តំណាងក្រសួងធនធានទឹកនិងឧតុនិយម ........ សមាជិក
១១- តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ........ សមាជិក
១២- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ........ សមាជិក
១៣- តំណាងក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ........ លេខាធិការប្រតិបត្តិ

**មាត្រា ២ :** គណកម្មការនេះ មានបេសកកម្ម ដូចខាងក្រោម :

-ពិភាក្សាលើបញ្ហាដែលកើតមានឡើង ក្នុងពេលអនុវត្តន៍កិច្ចព្រមព្រៀង រវាង រដ្ឋាភិបាលវៀតណាម និងរាជរដ្ឋាភិបាលកម្ពុជា ស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យសេដ្ឋកិច្ច ពាណិជ្ជកម្ម វិទ្យាសាស្ត្រ និង បច្ចេកទេសវិទ្យា និងកិច្ចព្រមព្រៀងវៀតណាម កម្ពុជាដទៃទៀត ក្នុងកិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម សេដ្ឋកិច្ច វិទ្យាសាស្ត្រ និងបច្ចេកទេសវិទ្យា ។

-សិក្សាពីលទ្ធភាពសំរាប់កិច្ចអភិវឌ្ឍន៍ថែមទៀត នូវកិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម សេដ្ឋកិច្ច វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ។

-ត្រៀមលក្ខណៈលើកសំណូមពរនានា ដើម្បីអនុវត្តប្រកបដោយជោគជ័យ នូវកិច្ចព្រមព្រៀងដែលបានព្រមព្រៀងខាងលើ និង សំណើស្តីពីវិធានការស្រួលក្នុងការជំរុញកិច្ចសហប្រតិបត្តិការក្នុងវិស័យទាំងនេះ ដើម្បីសុំការឯកភាពពីភាគីចុះកិច្ចសន្យា ក៏ដូចជាដោះស្រាយនូវបញ្ហាដទៃទៀត ដែលពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម សេដ្ឋកិច្ច វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ។

**មាត្រា ៣ :** ដើម្បីបំពេញបេសកកម្មខាងលើ គណកម្មការនេះមានភារកិច្ចនិងសិទ្ធិ :

-បង្កើតប្រតិទិនប្រចាំឆ្នាំមួយ សំរាប់អនុវត្តគំរោងផែនការ ដែលភាគីទាំងពីរបានឯកភាព ។

-ធ្វើរបាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាល ដើម្បីសុំគោលការណ៍ ឬ មតិណែនាំ ។

-សមាជិកនៃគណកម្មការ ត្រូវចូលរួមប្រជុំការងារ តាមការអញ្ជើញរបស់ប្រធាន ។

-មានសិទ្ធិប្រើត្រា នៃក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ក្នុងការអនុវត្តន៍ភារកិច្ចពាក់ព័ន្ធចាំបាច់ ។

**មាត្រា ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងសាធារណការ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម អគ្គលេខាធិការនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
ហ៊ុន សែន